# កម្មវិធីសប្បុរសធម៌នៅមជ្ឈមណ្ឌលសហសង្គ្រោះកម្ពុជា (Salvation Centre Cambodia-SCC) ស្ថិតនៅភូមិវាល សង្កាត់គោចក ក្រុង-ខេត្តសៀមរាប

នារសៀលថ្ងៃពុធ ៨រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងបេសកកម្មរៀបចំកម្មវិធីសិក្ខាសាលាបញ្ញាបការយល់ដឹងកម្រិតផ្ទៃក្នុងស្តីពី “ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សវនកររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ” និង “ការរៀបចំរបាយការណ៍សវនកម្មអនុលោមភាព” និងសិក្ខាសាលាស្តីពី “ការវាយតម្លៃអំពីប្រសិទ្ធភាព និងស័ក្តសិទ្ធភាពនៃផែនការសវនកម្មឆ្នាំ២០២២ និងវិបស្សនាដើម្បីរៀបចំផែនការសវនកម្មឆ្នាំ២០២៣” នៅខេត្តសៀមរាប ឯកឧត្តម ឈុន សម្បត្តិ ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អមដំណើរដោយសហការី បានឆ្លៀតពេលរៀបចំកម្មវិធីសប្បុរសធម៌នៅមជ្ឈមណ្ឌលសហសង្គ្រោះកម្ពុជា (Salvation Centre Cambodia-SCC) ស្ថិតនៅភូមិវាល សង្កាត់គោចក ក្រុង-ខេត្តសៀមរាប ដើម្បីជួបសំណេះសំណាលសួរសុខទុក្ខ និងបាននាំយកអំណោយជាគ្រឿងឧបភោគបរិភោគ និងសម្ភារៈសិក្សាមួយចំនួនជូនដល់កុមារកំព្រាដែលកំពុងរស់នៅក្នុងមជ្ឈមណ្ឌលផងដែរ។
















INTERNAL AUDIT UNIT



